## ជនរងគ្រោះដោយអំពីឧក្រិដ្ឋ មានកន្លែងបែរទៅរកជំនួយ

គណៈកម្មាការសំណងជនរងគ្រោះដោយអំពីឧក្រិដ្ឋ រដ្ឋមេនីសូតា (Minnesota Crime Victims Reparations) ជួយជនរងគ្រោះ និងគ្រួសារ របស់គេសំរាលបន្ទុកប្រាក់កាស ដែលគេប្រឈមមុខ បណ្តាលមកពីហិង្សាឧក្រិដ្ឋកម្ម ។

គណៈកម្មាការនេះផ្តល់ជំនួយប្រាក់កាស ដើម្បីចេញប្រាក់ឲ្យជនរងគ្រោះ សំរាប់ការខាតបង់ពីហោប៉ៅរបស់គេ ដែលបានកើតចេញផ្ទាល់ដោយសារឧក្រិដ្ឋកម្ម ។

## តើជនរងគ្រោះដាក់ពាក្យសុំសំណង ដោយរបៀបណា?

ជនរងគ្រោះអាចស្នើសុំក្រដាសបំពេញដាក់ពាក្យសុំ ដោយទូរស័ព្ទទៅការិយាល័យសំណង ។ ក្រដាសបំពេញដាក់ពាក្យសុំក៏អាចផ្ទេរយកពីវ៉ិបសៃរបស់យើងបានដែរ ។ ជនរងគ្រោះគួរតែទាក់ទងកម្មវិធីជំនួយជនរងគ្រោះ នៅក្នុងតំបន់របស់គេ សំរាប់ជំនួយក្នុងការបំពេញក្រដាសដាក់ពាក្យសុំ ។

ក្រដាសបំពេញដាក់ពាក្យសុំដែលបានបំពេញចប់ គួរតែបានផ្ញើ ឬក៏បញ្ជូនតាមទូរសារ ទៅការិយាល័យសំណង ។ ជនរងគ្រោះ គួរតែដាក់ពាក្យសុំយ៉ាងឆាប់រហ័សបំផុត ។ ការព្យាបាលសុខភាព ឬវិធីនៃតុលាការ មិនបាច់បានបំពេញនៅមុនពេលប្តឹងសុំសំណងទេ ។

## តើអ្នកណាខ្លះ ដែលមានសិទ្ធិដាក់ពាក្យសុំ?

- មនុស្សដែលមានរបួសរូបកាយ ឬគ្រាំគ្រាផ្លូវចិត្ត ឬស្លាប់ដោយសារឧក្រិដ្ឋកម្ម
- មនុស្សដែលបានរបួស ឬបានស្លាប់ ដោយព្រោះការខំព្យាយាមឃាត់ឃាំងឧក្រិដ្ឋកម្ម, ចាប់ជនសង្ស័យ, ឬជួយប៉ូលីស
- មនុស្សដែលបានបង់ថ្លៃសេវា(ការបំរើ) សំរាប់ជនរងគ្រោះ
- សមាជិកគ្រួសារ, អ្នកនៅក្នុងបន្ទុក, ឬអ្នកទទួលកេរអាករនៃជនរងគ្រោះ
- អ្នកអាណាព្យាបាល, អង្គការតំណាងអ្នកអាណាព្យាបាល, អ្នកការពារ ឬភ្នាក់ងារមានសមត្ថកិច្ចនៃអ្នកណាមួយទាំងនេះ

## តើប្រភេទឧក្រិដ្ឋកម្មអ្វីទៅ ដែលបានរ៉ាប់រង?

- មនុស្សឃាត
- ការវាយធ្វើបាប
- ការធ្វើបាបមនុស្សក្នុងគ្រួសារ
- ការរំលោភផ្លូវភេទ
- ការធ្វើបាបក្មេង (រូបកាយ ឬផ្លូវភេទ)
- ការចាប់មនុស្សជំរិតយកប្រាក់
- ការលួចដុតភ្លើង
- ការលួចប្លន់
- ការឃាយី/ការដើរតាមឈ្លបចាប់
- បទឧក្រិដ្ឋបុកគេ ហើយរត់គេច
- ការបើកបររថយន្តក្រោមអានុភាពនៃគ្រឿងស្រវឹង
- ឧក្រិដ្ឋជននៃការដឹកនាំរថយន្ត

ឧក្រិដ្ឋកម្មខាងទ្រព្យសម្បត្តិ គឺមិនរ៉ាប់រងទេ ។

## តើមានជំនួយអ្វីខ្លះ?

វាមានកំរិតទៅលើជំនួយនៅខាងក្រោមសឹងតែទាំងអស់ ហើយជំនួយរួមមិនអាចនឹងលើសពី 50,000 សំរាប់ជនរងគ្រោះម្នាក់ៗឡើយ ។

- ការចំណាយខាងពេទ្យ – មន្ទីរពេទ្យ, គ្រូពេទ្យ, ឡានពេទ្យ, ការចាត់ចែងថ្នាំពេទ្យ, ឱសថមានវេជ្ជបញ្ជា, ការថែទាំដោយចាប់សរសៃនិងសន្លាក់ឆ្អឹង, ប្រដាប់ប្រើជំនួយអវយវៈ
- ការចំណាយខាងការប្រឹក្សា សំរាប់ជនរងគ្រោះ និងសមាជិកគ្រួសាររបស់គេ
- ការចំណាយខាងបុណ្យសព – សេវានៃបុណ្យសព, ការបូជាសព, ការបញ្ចុះសព, ថ្មតាំងលើក្បាលផ្នូរសព, ផ្កា, ការចុះផ្សាយដំណឹងមរណភាព, ទីសំណាក់ និងការធ្វើដំណើរសំរាប់សមាជិកគ្រួសារ ដើម្បីទៅចូលរួមពិធីបុណ្យសព
- ការខាតបង់ប្រាក់ថ្លៃឈ្នួលធ្វើការ ដោយព្រោះការពិការរូបកាយ ឬការគ្រាំគ្រាផ្លូវចិត្ត
- ការអស់នូវការគាំទ្រអ្នកនៅក្នុងបន្ទុក (ប្តីឬប្រពន្ធ/ដៃគូក្នុងគ្រួសារ និងកូនក្មេងវ័យ) នៃជនរងគ្រោះការសំឡាប់មនុស្ស
- ការមើលថែក្មេង និងសេវាពីអ្នកវិជ្ជាជីវៈ សំរាប់មនុស្សក្នុងគ្រួសារ ដើម្បីជំនួសសេវាដែលបានផ្តល់ដោយជនរងគ្រោះនៅមុនពេលមានឧក្រិដ្ឋកម្ម
- តម្លៃយានជំនិះ, ម្ហូបអាហារ និងទីសំណាក់ ដើម្បីឲ្យកូនដែលគេបានពង្រត់វិលត្រឡប់មកវិញ
- ការសំអាតកន្លែងឧក្រិដ្ឋកម្ម

ការឈឺចាប់ និងការវេទនា, និងការខូតខាត ទោះជាប្រាក់ ឬទ្រព្យដែលគេលួច គឺមិនរ៉ាប់រងទេ ។

## តើសេចក្តីតម្រូវនៃសិទ្ធិទទួលមានអ្វីខ្លះ?

- ឧក្រិដ្ឋកម្ម ត្រូវតែបានកើតឡើងក្នុងរដ្ឋមេនីសូតា ឬនៅឯបរទេស ដែលពុំមានកម្មវិធីការសងប្រាក់ឲ្យវិញ
- ឧក្រិដ្ឋកម្ម ត្រូវតែបានរាយការណ៍ទៅប៉ូលីស ក្នុងរយៈពេល 30 ថ្ងៃ (គ្មានកំរិតពេលសំរាប់ការរំលោភផ្លូវភេទ និងក្មេងៗដែលរងគ្រោះដោយការធ្វើបាប ប៉ុន្តែឧក្រិដ្ឋកម្មត្រូវតែបានរាយការណ៍)
- ជនរងគ្រោះ ត្រូវតែសហការដោយពេញលេញ ជាមួយនឹងប៉ូលីស នៅក្នុងការស៊ើបអង្កេតរបស់គេ និងជាមួយមេធាវីក្រុង ឬ ខោនធី ក្នុងការយកជនល្មើសច្បាប់មកផ្តោលទោស
- ក្រដាសបំពេញដាក់ពាក្យសុំត្រូវតែបានបញ្ជូនមក ក្នុងរយៈពេល 3 ឆ្នាំ នៃពេលមានបទឧក្រិដ្ឋ (ការប្តឹងទាមទារនៃការធ្វើបាបក្មេង ត្រូវតែបានប្តឹងក្នុងរយៈពេល 3 ឆ្នាំ នៃថ្ងៃបានរាយការណ៍ឧក្រិដ្ឋកម្មទៅប៉ូលីស)
- ជនរងគ្រោះ មិនត្រូវបានប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានរួមចំណែកប្រព្រឹត្តអំពើល្មើសច្បាប់ តាមរយៈការប្រព្រឹត្តខុសឆ្គងរបស់គេឡើយ
- ប្រភពនៃការធានាដែលមានទាំងអស់ ត្រូវតែបានប្រើជាមុនសិន, រួមទាំងការធានារ៉ាប់រងសុខភាព, ជំនួយពេទ្យ, ការធានារ៉ាប់រងរថយន្ត, ប្រាក់វិស្សមកាល/ការឈឺ, ប្រាក់ពិការរយៈខ្លីឬយូរអង្វែង, ប្រាក់ជំនួយសូស្យ៉ាល់សឺគ្យូរិទី ជាដើម ។ល ។

*សូមកំណត់ : សៀវភៅឃោសនា គឺមានបំណងដើម្បីផ្តល់ព័ត៌មានជាទូទៅសំរាប់អ្នក អំពីកម្មវិធីសំណង ។ វាមិនបានបញ្ចូលនូវសេចក្តីតម្រូវទាំងអស់ នៃក្រឹត្យសំណងជនរងគ្រោះដោយអំពីឧក្រិដ្ឋ រដ្ឋមេនីសូតាឡើយ ។*

### សូមទាក់ទងយើង


Office of Justice Programs
Crime Victims Reparations Board
445 Minnesota Street, Suite 2300
St. Paul, MN 55101-1515

អ៊ីមៀល : dps.justiceprograms@state.mn.us
វ៉ិបសៃ : www.ojp.state.mn.us

651-201-7300 លេខចំបង
888-622-8799 លេខឥតចេញថ្លៃ
651-205-4827 TTY
651-296-5787 ទូរសារ


9/07

# ជំនួយប្រាក់កាស សំរាប់ជនរងគ្រោះ នៃហិស្សឧក្រិដ្ឋកម្ម

គណៈកម្មាការសំណាងជនរងគ្រោះដោយអំពីឧក្រិដ្ឋ រដ្ឋមេនីសូតា



**ការិយាល័យនៃកម្មវិធីយុត្តិធម៌**

ក្រសួងសុវត្ថិភាពសាធារណៈ រដ្ឋមេនីសូតា